**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤៤២ ព.ណ.ភ.ព

ថ្ងៃសុក្រ ៩ រោច ខែបឋមាសាឍ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ពាណិជ្ជករ អាជីវករ និងសាធារណជនទូទៅឲ្យបានជ្រាបថា៖ សហព័ន្ធសមាគមពាណិជ្ជកម្ម នៃទីក្រុងហូជីមិញ នឹងរៀបចំពិព័រណ៍ "2th ASEAN Expo 2018 in Ho Chi Minh City" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៨ ដល់ ២២ ខែកក្កដា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលតាំងពិព័រណ៍ទិនប៊ិន (Tan Binh Exhibition & Convention Center-TBECC) ទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញពាណិជ្ជករ អាជីវករ ដែលជាម្ចាស់ក្រុមហ៊ុន និងសហគ្រាសទាំងអស់ ដែលមានបំណងទៅចូលរួមផ្សព្វផ្សាយពីផលិតផលរបស់ខ្លួន ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្មក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ សូមមកទាក់ទង និងបំពេញបែបបទនៅនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ត្រឹមថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ដោយភ្ជាប់មកជាមួយនូវពាក្យស្នើសុំចូលរួម និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងស្ថិតនៅជាន់ទីពីរ នៃអគារទីស្តីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០១២ ៧០៣ ៣៩៣ ឬ ០១២ ៧៧៧ ៩៥៩ ឬ ០១២ ៦០០ ៧៧៨

អាសយដ្ឋានអ៊ីម៉ែល៖ sopheap.sok56789@gmail.com ឬ cheaputhea@yahoo.com

veasna_mao@yahoo.com

**សូមអរគុណ**

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N° 2442 MOC D.I.EA..

Phnom Penh, 6 July, 2018

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform the Traders and Business people that Ho Chi Minh City Union of Business Association and The People's Committee of Tan Binh District will organize the **"2nd ASEAN EXPO 2018 in Ho Chi Minh City"**, which will be held from 18th to 22th July, 2018 at Tan Binh Exhibition & Convention Center-TBECC Socialist Republic of Viet Nam.

In this regard, the Ministry of Commerce has the honor to invite all the owner of Companies and Enterprises who wish to advertise their products or to look for trading partners in this event, please kindly contact and register at Department of Exhibition Affairs of the General Directorate of Trade Promotion, The Ministry of Commerce by filling in application form and other related documents by 12th July, 2018 at the latest stage.

For other detailed information related to participation in the above-mentioned exhibitions, please kindly contact: Department of Exhibition Affairs, General Directorate of Trade Promotion, Lot No. 19-61, Russian Federation Blvd, Phum Toek Thla, Sangkat Toek Thla, Khan Sen Sok, Phnom Penh, or Via the following:

Tel: 012 703 393 / 012 777 959 / 012 600 778

E-mail: sopheap.sok56789@gmail.com / cheaputhea@yahoo.com
veasna_mao@yahoo.com

THANK YOU!